សហគមន៍ និងយុត្តិធម៌ (Communities and Justice)

ជាភាសាខ្មែរ
Khmer



# កម្មវិធីផ្តល់ប្រាក់ដល់សហគមន៍ពហុវប្បធម៌ឆ្នាំ 2023៖ ដើម្បីទទួលស្គាល់ និងឆ្លើយតបនឹងអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាគ្រួសារ និងអំពើហិង្សាខាងផ្លូវភេទ

រដ្ឋាភិបាលរដ្ឋ NSW (NSW Government) កំពុងប្រកាសអំពីកម្មវិធីផ្តល់ប្រាក់ដល់សហគមន៍ពហុវប្បធម៌លើអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាគ្រួសារ និងអំពើហិង្សាខាងផ្លូវភេទ។

ការផ្តល់មូលនិធិមានទឹកប្រាក់សរុប $2,000,000 អាចមានសម្រាប់ការផ្តល់ប្រាក់តែមួយដងនៃការផ្តល់ប្រាក់ទាំងនេះ។

អ្នកដាក់ពាក្យសុំការផ្តល់ប្រាក់បានជោគជ័យត្រូវតែបង្កើតសមត្ថភាពនៃសហគមន៍ពហុវប្បធម៌នានា ដើម្បីទទួលស្គាល់ និងឆ្លើយតបនឹងអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាគ្រួសារ និងអំពើហិង្សាខាងផ្លូវភេទ។

មានតែអង្គការសហគមន៍ដែលមិនរកកម្រៃជាសាជីវកម្មនៅរដ្ឋ NSW ប៉ុណ្ណោះអាចដាក់ពាក្យសុំសម្រាប់មូលនិធិនៃការផ្តល់ប្រាក់ទាំងនេះ។

ប្រសិនបើអ្នកមិនមែនជាអង្គការសហគមន៍មិនរកកម្រៃមិនមែនជាសាជីវកម្មទេ អ្នកអាចធ្វើជាដៃគូជាមួយអង្គការមួយដែលមានសិទ្ធិទទួលបាន។

អ្នកត្រូវតែបំពេញបានយ៉ាងតឹងរឹងទៅតាមគោលការណ៍នៃការផ្តល់ប្រាក់ដើម្បីដាក់ពាក្យសុំសម្រាប់មូលនិធិនានា ដែលមានទឹកប្រាក់ចាប់ពី $20,000 - $150,000។
ការដាក់ពាក្យសុំបើកនៅថ្ងៃទី 13 ខែកុម្ភៈ ឆ្នាំ 2023 ហើយបិទ នៅម៉ោង 5 ល្ងាចថ្ងៃ ទី 27 ខែមីនា ឆ្នាំ 2023។
ដើម្បីយល់បន្ថែមអំពីការផ្តល់ប្រាក់ទាំងនេះ សូមចូលមើល៖ https://www.dcj.nsw.gov.au/service-providers/grants/domestic-family-sexual-violence-multicultural-community-grant.html

ប្រសិនបើអ្នកត្រូវការដំបូន្មានស្តីអំពីកម្មវិធីនៃការផ្តល់ប្រាក់នេះ អ្នកអាចទាក់ទងក្រុមការងារផ្តល់ប្រាក់ពហុវប្បធម៌ DFSV (DFSV Multicultural Grants delivery team) តាមអ៊ីមែលទៅ WFCS.DFSVMulticulturalGrant@facs.nsw.gov.au។

រដ្ឋាភិបាលរដ្ឋ NSW សូមស្វាគមន៍ដល់ការដាក់ពាក្យសុំសម្រាប់ការផ្តល់ប្រាក់របស់អ្នក ពីព្រោះអ្នកដឹងថាអ្វីខ្លះដែលដំណើរការបានល្អបំផុតសម្រាប់សហគមន៍របស់អ្នក។



NSW GOVERNMENT